## ៥. កំណែទម្រង់ស្ថាប័ន និង ការកសាងសមត្ថភាព

### ៥.១ សេចក្តីសង្ខេបការរីកចំរើនឆ្នាំ២០០១-២០០៤

ការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៣ បានបង្ហាញថាមានការរីកចំរើនជាច្រើន រួមមាន : ក) សាលារៀនបានកែលំអមធ្យោបាយក្នុងការអនុវត្តសកម្មភាពរបស់ កម្មវិធីសកម្មភាពជាអាទិភាព ខ) តាំងពីឆ្នាំ២០០០មក គុណភាពនៃការចំណាយបានកើនឡើង (សាលារៀនប្រើប្រាស់ថវិកាត្រឹមត្រូវ) គ) ចាប់ពីខែតុលា ឆ្នាំ២០០២មក មានគោលការណ៍ណែនាំច្បាស់លាស់សំរាប់ការចំណាយថវិកា កសអ (រួមមាន អនុក្រឹត្យ និងប្រកាសអន្តរក្រសួង) ឃ) ចាប់ពីឆ្នាំ១៩៩៧មក ថវិកាសរុបសំរាប់វិស័យអប់រំបានកើនឡើង ដូចជាចំណាយឯកតាសំរាប់សិស្សម្នាក់ និងជាភាគរយនៃចំណាយសរុបរបស់រាជរដ្ឋាភិបាល ។

ការងារគ្រប់គ្រងហិរញ្ញវត្ថុក៏មានការរីកចំរើនផងដែរដូចជា ក) ប្រព័ន្ធរបាយការណ៍របស់កម្មវិធីសកម្មភាពជាអាទិភាព ត្រូវបានពិនិត្យនិងបញ្ជូនមកកែលំអត្រង់ផ្នែកដែលចាំបាច់ ខ) ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវបានបង្កើតឡើង គ) ក្រុមសវនកម្មផ្ទៃក្នុងបានបង្កើតសំរាប់ចុះពិនិត្យតាមដានការចំណាយ ដែលមានការទទួលខុសត្រូវ មានតំលាភាព និងភាពសន្សំសំចៃ។ ការរីកចំរើនមួយទៀត គឺការកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ ពិសេសការកែលំអការប្រាស្រ័យទាក់ទង ការបង្កើនសម្ភារបរិក្ខារ និងសិក្ខាសាលាបំប៉នដល់មន្ត្រីបំរើការនៅតាម BMC។ ប្រព័ន្ធ គ្រោងថវិកាក៏ត្រូវបានពង្រឹង ដែលជាផ្នែកមួយឆ្ពោះទៅរកការគ្រប់គ្រងផ្អែកលើលទ្ធផល និងមានតំលាភាពកាន់តែច្រើនឡើង។ ការបំប៉នរួមមាន ផ្នែកភាសាបរទេស បច្ចេកវិទ្យាពត៌មាន និងមុខជំនាញបច្ចេកទេសផ្សេងទៀត ។

ការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៣ បានរកឃើញបញ្ហាមួយចំនួនដូចជា ក) មានការលំបាកក្នុងការពង្រាយគ្រូទៅតាមសាលារៀន ដែលមានចំនួនបុគ្គលិកហួសកំណត់ ខ) មានការលំបាកក្នុងការសំរបសំរួលគ្នា នៅពេលមាននាយកដ្ឋានជាច្រើនបានចូលពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាពដូចគ្នា គ) ការងាររដ្ឋបាលយឺតយ៉ាវដោយសារផ្នែកគមនាគមន៍។ បញ្ហាសំខាន់៧ចំពោះការងារគ្រប់គ្រងហិរញ្ញវត្ថុដែលទាមទារអោយមានការដោះស្រាយរួមមាន : ១) ការកែលំអរបាយការណ៍ហិរញ្ញវត្ថុ ២) ការបង្កើត BMCs នៅតំបន់ដាច់ស្រយាល ៣) ដំណើរការការងារសវនកម្មផ្ទៃក្នុង ។

### ៥.២ សកម្មភាពកសាងសមត្ថភាពសំខាន់ៗ

ក្រសួងអប់រំ យុវជន និងកីឡាបានចាត់វិធានការអនុវត្តតាមអនុសាសន៍មួយចំនួន ដែលបានលើកឡើង នាពេលពិនិត្យឡើងវិញឆ្នាំ២០០៣ រួមមាន :

- គោលវិធីទូលំទូលាយ និងមានលក្ខណៈសំរបសំរួល ដល់ផែនការសកម្មភាពសំរាប់ការកសាងសមត្ថភាព និងការអនុវត្តកម្មវិធី តាមរយៈក្រុមសំរបសំរួលការកសាងសមត្ថភាព នៅតាមអគ្គនាយកដ្ឋានីមួយៗ រួមទាំងថ្នាក់ខេត្ត-ក្រុងផងដែរ ។

- បញ្ចប់ការរៀបចំសេចក្ដីព្រាងច្បាប់អប់រំ និងបទបញ្ញត្តិនានា ដែលនឹងត្រូវពិនិត្យឡើងវិញនៅចុងឆ្នាំ២០០៤ និងសុំការអនុម័តជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំ២០០៥។
- ពង្រីកកម្មវិធីបំប៉នសំរាប់បុគ្គលិករដ្ឋបាលកណ្ដាល ថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងនាយកសាលារៀនលើការងារ ក) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ខ) ការពិនិត្យតាមដានកម្មវិធី គ) ការគ្រប់គ្រងពត៌មាន។
- ពង្រីកសមត្ថភាពរបស់ IEC តាមរយៈ ក) ការពង្រីក website របស់ក្រសួងអប់រំ យុវជន និង កីឡា ខ) ការពង្រីកវិសាលភាពរបស់យុទ្ធនាចុះឈ្មោះចូលរៀន ដោយយកចិត្តទុកដាក់លើសិស្សស្រី និងជនជាតិភាគតិច គ) បង្កើនការយកចិត្តទុកដាក់លើពត៌មាននៃការគ្រប់គ្រងផ្អែកលើលទ្ធផល ។
- ពង្រឹងអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដំណើរការសវនកម្មគំរូ (sample audits) នៅBMCថ្នាក់កណ្ដាល BMCខេត្ត-ក្រុង BMCស្រុក-ខ័ណ្ឌ និងសាលារៀន ។
- ពង្រឹង និងពង្រីកការពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ ជាពិសេសគុណភាព និងប្រសិទ្ធភាពអប់រំ
- រៀបចំលិខិតបទដ្ឋានសំរាប់ការងារគ្រប់គ្រង និងប្រើប្រាស់ថវិកាលើគ្រប់ជំពូកចំណាយ។
- រៀបចំការប្រជុំផ្លាស់ប្ដូរយោបល់ បទពិសោធន៍ និងផ្ដល់អនុសាសន៍លើការងារ និងប្រើប្រាស់ថវិកាគ្រប់ជំពូកចំណាយ ជាពិសេសកម្មវិធីសកម្មភាពជាអាទិភាពនៅតាមខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ។
- បណ្ដុះបណ្ដាលមន្ត្រីឯកទេសក្នុងការកសាង និងអនុវត្តកម្មវិធីសិក្សានៅថ្នាក់កណ្ដាល និងខេត្ត-ក្រុង។

បន្ថែមពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាបានពង្រីកកម្មវិធីបំប៉នរបស់ខ្លួនសំរាប់ការងារគ្រប់គ្រង និងការពិនិត្យតាមដានរួមមាន : ក) ការបំប៉ននាយកសាលារៀន គ្រូឧទ្ទេស និងអ្នកសំរបសំរួលកំរងសាលារៀន ខ) ការរៀបចំការងាររដ្ឋបាល និងការគ្រប់គ្រងក្នុងការប្រលង គ) ការអនុវត្តសាលារៀនកុមារមេត្រី ការអប់រំបញ្ចូលគ្នា និងបរិស្ថានសាលា ឃ) កែលំអការគ្រប់គ្រងកម្មវិធីសកម្មភាពជាអាទិភាពមួយចំនួន ង) បំប៉នសមត្ថភាពកិច្ចការរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ ច) ពង្រឹងការងារទំនាក់ទំនងរវាងអ្នកផ្ដល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួងអប់រំ យុវជន និងកីឡា។

## ៥.៣ និរន្តរភាពនៃការកសាងសមត្ថភាពសំរាប់វិមជ្ឈការ

បទពិសោធន៍ដែលទទួលបានគឺ ការផ្ដល់សិទ្ធិអំណាច និងទំនួលខុសត្រូវ គឺជាផ្នែកមួយនៃការកសាងសមត្ថភាព និងការរៀបចំកម្មវិធីបណ្ដុះបណ្ដាលនៅនឹងកន្លែងតាមរយៈកំរងសាលារៀន និងកម្មវិធីបណ្ដុះបណ្ដាលផ្លូវការ។ បទពិសោធន៍ផ្សេងទៀតនោះគឺ បានបង្ហាញពីការអនុវត្តនៃការផ្ដល់សិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាព ដែលទាមទារអោយមានទំនុកចិត្ត មាននិរន្តរភាពក្នុងការគាំទ្រថវិកាដំណើរការ និងការផ្ដល់ហិរញ្ញប្បទាន។ ត្រូវការប្រើប្រាស់ពេលវេលាជាច្រើនក្នុងការផ្ទេរសិទ្ធិអំណាច ដើម្បីធ្វើអោយយល់បានច្បាស់លាស់ ព្រមទាំងកំណត់អោយច្បាស់ពីតួនាទី និងការទទួលខុសត្រូវថ្មី ពិសេសរវាងនាយកដ្ឋានក្រោមឱវាទក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ។

បទពិសោធន៍ផ្សេងទៀត គឺត្រូវពង្រឹងស្ថាប័ន និង កសាងសមត្ថភាពនៅថ្នាក់ក្រោមបំផុត ជាពិសេសការពិនិត្យឡើងវិញពីតួនាទីនិងមុខងារនៅថ្នាក់ស្រុក-ខ័ណ្ឌ និង សហគមន៍ ដើម្បីធានាអោយការបញ្ជូនព័ត៌មានដែលពាក់ព័ន្ធនឹងគោលនយោបាយ និងការរីកចំរើនក្នុងការអនុវត្តកម្មវិធីបានទាន់ពេលវេលា និងមានប្រកបដោយប្រសិទ្ធិភាព។ ច្បាប់អប់រំមានសារៈសំខាន់ ក្នុងការបង្កើនការទទួលខុសត្រូវ និង ការផ្តល់សិទ្ធិអំណាចទាំងនេះ ។

ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡានឹងអនុវត្តយុទ្ធសាស្ត្រសំខាន់ចំនួន៤ សំរាប់ការអភិវឌ្ឍន៍ស្ថាប័ន និងកំណែលំអកម្មវិធីកសាងសមត្ថភាពសំរាប់ធ្វើវិមជ្ឈការការងារ ដូចជា ក) ពង្រឹងប្រព័ន្ធកសាងផែនការ និង ពិនិត្យតាមដាននៅថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ កំរងសាលារៀន និងសាលារៀន ខ) លើកកំពស់ប្រព័ន្ធគ្រប់គ្រងការិយាល័យអប់រំស្រុក និងសាលារៀន គ) កែលំអអភិបាលកិច្ចល្អ និងប្រព័ន្ធច្បាប់ ឃ) កែលំអការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា និងការកសាងសមត្ថភាព។ គ្រប់ការងារទាំងអស់នេះ យើងបានយកចិត្តទុកដាក់លើការងារគ្រប់គ្រងហិរញ្ញវត្ថុ។